# សន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្មប្រចាំឆ្នាំ២០១៤

# និងទិសដៅអនុវត្តបន្តឆ្នាំ២០១៥








សន្និបាតបូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្មប្រចាំឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៥ ត្រូវបានប្រារព្ធធ្វើឡើងរយៈពេល ០៣ថ្ងៃ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០១៥ នៅសាលប្រជុំរដ្ឋាកទឹកភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួងយ៉ាងច្រើនកុះករ ។




មានប្រសាសន៍បើកអង្គសន្និបាត ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងទឹកចិត្តរីករាយ និងចាត់ទុកការរៀបចំសន្និបាតនេះគឺស្របពេល ដែលស្ថានភាពនយោបាយរបស់ប្រទេសជាតិ កំពុងវិវឌ្ឍន៍ទៅប្រកបដោយលក្ខណៈស្ថិរភាពល្អប្រសើរ សន្តិសុខសណ្តាប់ធ្នាប់ត្រូវបានធានា ដែលអំណោយផលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើគ្រប់វិស័យ ។ កត្តានេះបានធ្វើឱ្យកម្ពុជាអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ជាង៧% ក្នុងរយៈពេល ៣-៤ ឆ្នាំចុងក្រោយនេះ ។និងបានផ្តល់លទ្ធភាពជាផ្លែផ្កា ក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ដោយនាំមកនូវវិបុលភាព វឌ្ឍនភាពដល់ប្រទេសទេសជាតិ និងប្រជាជនយើង ។

ក្នុងនាមថ្នាក់ដឹកនាំក្រសួង និងក្នុងនាមឯកឧត្តមផ្ទាល់ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងនូវមោទនភាពចំពោះសមិទ្ធិផលទាំងឡាយដែលក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រេចបានរយៈពេលមួយឆ្នាំដំបូងនៃអណត្តិទី៥ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានវាយតម្លៃខ្ពស់ចំពោះមន្ត្រីក្រោមឱវាទក្រសួងគ្រប់អង្គភាព គ្រប់ជាន់ថ្នាក់ ដែលក្នុងរយៈពេលជាងមួយឆ្នាំនេះ បានលះបង់កំលាំងកាយចិត្ត និងធន់ធានជាច្រើន ខិតខំបំពេញភារកិច្ច ដោយស្មារតីទទួលខុសត្រូវខ្ពស់ រួមចំណែកសម្រេចបាននូវលទ្ធផលស្នាដៃជាច្រើនជូនរាជរដ្ឋាភិបាល និងប្រជាជន ។ កាលពីដើមខែកក្កដា ឆ្នាំទៅក្រសួងបានដំណើរការ

កិច្ចប្រជុំផ្ទៃក្នុងមួយ ដើម្បីត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារ ក្នុងឆមាសទី១ ឆ្នាំ២០១៤ និងលើកទិសដៅអនុវត្តការងារបន្ត និងបន្ទាប់មកនៅខែតុលា កន្លងទៅ ក្រសួងបានរៀបចំកិច្ចប្រជុំផ្ទៃក្នុងមួយទៀត ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្នុងរយៈពេលមួយឆ្នាំ នៃការបង្កើតរាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ដែលពាក់ព័ន្ធ និងវិស័យឧស្សាហកម្ម និងសិប្បកម្ម ក៏ដូចជាការងារពង្រឹងការគ្រប់គ្រងស្ថាប័ន ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ។ ផ្តើមចេញពីនេះ យើងបានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួន នូវទិសដៅជាយុទ្ធសាស្ត្រ នៃកំណែទម្រង់នេះ ដែលបានដាក់ចេញនូវវិធានការចាត់តាំងអនុវត្តជាបន្តបន្ទាប់ ដែលរហូតមកដល់ពេលនេះទាមទារឱ្យយើងរួមគ្នាពិនិត្យ ឡើងវិញនូវចំនុចសេសសល់ទាំងឡាយរួមទាំងការដកស្រង់បទពិសោធន៍ការងារ សម្រាប់រួមគ្នាកែលម្អរ និងលើកទិសដៅអនុវត្តឱ្យចំផែនការ និងមានប្រសិទ្ធិភាព ។ ក្រៅពីកិច្ចការចរន្តប្រចាំថ្ងៃ ក្រសួងក៏បានរៀបចំចាត់តាំងមន្ត្រី ចាប់តាំងពីថ្នាក់អគ្គនាយករងឡើងទៅឱ្យចូលរួមក្នុងក្រុមការងារថ្នាក់ជាតិចុះតាមមូលដ្ឋានរាជ ធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ទូទាំងប្រទេស ដើម្បីក្តាប់សំណូមពរផ្សេងៗនិងជួយដោះស្រាយបញ្ហាកង្វល់នានាជូនពួកគាត់ ក្នុងដែនសមត្ថកិច្ចរបស់ក្រសួង និងពាំនាំសំណូមពរទាំងនេះ ទៅក្រសួងស្ថាប័ន ពាក់ព័ន្ធ ដើម្បីជម្រុញការឆ្លើយតបរបស់ ប្រជាពលរដ្ឋតាមមូលដ្ឋាន ក្នុងគោលដៅពង្រឹងការគាំទការអនុវត្តយុទ្ធសាស្តចតុកោណដំនាក់កាលទី៣ របស់រាជរដ្ឋាភិខាលឱ្យសម្រេចខានជោគជ័យ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសង្កត់ធ្ងន់ថា:ឥឡូវនេះ រាល់កិច្ចការអ្វីៗទាំងអស់ត្រូវនិយាយពីប្រសិទ្ធិភាពការងារ តាមគោលដៅ ដែលយើងចង់បាន ដែលជាខ្នាតសម្រាប់ធ្វើការវាយតម្លៃទៅលើសមត្ថភាពបំពេញការងារ របស់អង្គភាព និងមន្ត្រីគ្រប់ផ្នែក គ្រប់ថ្នាក់ ។ នេះជាប្រសាសន៍រំលឹកណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ដែលបានថ្លែង ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបការងាររបស់ក្រុមការងារថ្នាក់ជាតិ នៅវិមានសន្តិភាព កាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៥ នាពេលថ្មីៗនេះ ។ ហេតុនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើដល់សមាជិក-សមាជិកា នៃអង្គសន្និបាតទាំងអស់សូមយកឱកាសដ៏មានតម្លៃនៃការជួបជុំគ្នា ពីគ្រប់អង្គភាពទាំងនៅរដ្ឋបាលកណ្តាល និងតំណាងពីថ្នាក់ខេត្ត ថ្នាក់ក្រោមជាតិ ផ្តោតការយកចិត្តទុកដាក់ឱ្យបានច្រើន ទៅលើខ្លឹមសារគោលសំខាន់ៗ ដេលបានដាក់បញ្ចូល នៅក្នុងរបាយការណ៍ ក្តាប់បញ្ហាជាចំនុច

ប្រឈមធំៗ និងទិសដៅចំបងៗ ដែលមានលក្ខណៈជាអាទិភាព ពាក់ព័ន្ធ និងវិស័យជំនាញរបស់ខ្លួន ដើម្បីផ្តល់មតិជូនអង្គសន្និបាតវិញ ។



បន្ទាប់មកអង្គសន្និបាតបានតាមដានស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារសំខាន់ៗរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៤ និងលើកទិសដៅអនុវត្តការងារបន្ត ដែលអានដោយ ឯកឧត្តម មាន សុភា អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាបន្តបន្ទាប់ គឺជាបទអន្តរាគមន៍ របស់បណ្តាប្រធានមន្ទីរជុំវិញ ២៥ ខេត្ត–រាជធានី ប្រធាននាយកដ្ឋាន អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងបទអន្តរាគមន៍ពីថ្នាក់ដឹកនាំក្រសួងផងដែរ ។

នៅព្រឹកថ្ងៃទី៨ ខែ មេសា ឆ្នាំ ២០១៥ បន្ទាប់ពីជួបពិភាក្សាដោយឡែករយៈពេលខ្លីជាមួយថ្នាក់ដឹកនាំក្រសួងរួចមក ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានអញ្ជើញមានមតិ បកស្រាយ ព្រមទាំងពិនិត្យដោះស្រាយសំណូមពរ និងបញ្ហាប្រឈមទាំងឡាយ ក៏ដូចជា ដាក់វិធានការនានា និងលើកទិសដៅអនុវត្តបន្ត ដើម្បីជាមូលដ្ឋានគ្រឹះដល់សមាជិក–សមាជិកា អង្គសន្និបាតទាំងអស់យកទៅអនុវត្តឱ្យចំគោលដៅ តម្លាភាព ការទទួលខុសត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ។ ជាពិសេស ក្នុងឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម

ប្រសិទ្ធ បានសម្រេចធ្វើប្រតិភូកម្មអំណាចនូវការងារចាំបាច់ជាច្រើន ដល់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្ត រាជធានី ដើម្បីបង្កើនសកម្មភាពរស់រវើក នៃវិស័យឧស្សាហកម្ម និងសិប្បកម្មកម្ពុជាតាមមូលដ្ឋាន ខេត្ត ក្រុង ។ ដោយឡែក ទាក់ទង និងទិសដៅអនុវត្តបន្ត ក្រៅពីការងារចរន្ត និងការងារស្នូលចាំបាច់ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានណែនាំឱ្យអង្គសន្និបាតយកចិត្តទុកដាក់ ខិតខំរៀបចំខ្លួន ជាមួយនិងវិធានការគ្រប់បែបយ៉ាង ដើម្បីចូលរួមអនុវត្តឱ្យបានជោគជ័យនូវគោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ពីឆ្នាំ២០១៥-២០២៥ ដែលគោលនយោបាយនេះ សម្តេច តេជោនាយករដ្ឋមន្ត្រី នឹងធ្វើការប្រកាសផ្សព្វផ្សាយក្នុងវេទិការវាងរដ្ឋាភិបាល និងវិស័យឯកជន នាពេលខាងមុខនេះ ។

មានប្រសាសន៍បិទអង្គសន្និបាត ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានវាយតម្លៃខ្ពស់ចំពោះលទ្ធផល នៃដំណើរការអង្គសន្និបាតរយៈពេល ០៣ថ្ងៃប្រកបដោយជោគជ័យ ជាពិសេសគឺសមិទ្ធិផលដែលក្រសួងសម្រេចបាន រយៈពេលមួយឆ្នាំកន្លងទៅ ដែលឯកឧត្តម បានរំលេចចេញដូចជាៈការរៀបចំកែសម្រួលរចនាសម្ព័ន្ធថ្មីរបស់ក្រសួង-ការពន្លឿនការអភិវឌ្ឍន៍នៃវិសាលភាពវិស័យទឹកស្អាត-ការគ្រប់គ្រងការចុះបញ្ជីសហគ្រាសធន់តូច និងមធ្យម និងសិប្បកម្ម តាមយន្តការច្រក ចេញចូលតែមួយ-ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម-បង្កើតបាននូវស្តង់ដារ ផលិតផលម្ហូបអាហារ និងឧបករណ៍សំភារៈប្រើប្រាស់ ជាដើម ។


សន្និបាត
បូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៤
និងទិសដៅអនុវត្តការងារឆ្នាំ២០១៥


សន្និបាត
បូកសរុបលទ្ធផលការងារក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប្រចាំឆ្នាំ២០១៤
និងទិសដៅអនុវត្តការងារឆ្នាំ២០១៥
ថ្ងៃទី ០៦-០៨ ខែមេសា ឆ្នាំ២០១៥


សន្និបាត


សន្និបាត

តមកនៅរសៀលថ្ងៃទី០៨ ខែ ឆ្នាំដដែល ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ និងថ្នាក់ដឹកនាំទាំងអស់បានអញ្ជើញផ្តល់កិត្តិយស បំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា និងមេដាយការងារ ដល់មន្ត្រីរាជការក្រោមឱវាទក្រសួងចំនួន៤០២នាក់ ។

សូមបញ្ជាក់ថាៈបន្ទាប់ពីបញ្ចប់អង្គសន្និបាតទៅ ក្រសួងបានអនុញ្ញាតឱ្យសមាសភាព ដែលខានចូលរួមក្នុងអង្គសន្និបាត បន្តចូលរួមវគ្គបណ្តុះបណ្តាលផ្ទៃក្នុងក្រសួង រយៈពេល០២ថ្ងៃទៀត ក្នុងគោលបំណងបង្កើនចំណេះដឹង និងពង្រឹងសមត្ថភាព ជូនមន្ត្រីរាជការ អំពីការអនុវត្តតួនាទី ភារកិច្ច តាមវិស័យជំនាញ និងពង្រឹងការយល់ដឹងពីវិស័យច្បាប់មួយចំនួន ជាពិសេសអត្ថបទទាក់ទង ទៅនិងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥–២០២៥ ការងារទាក់ទង និងសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ការតម្រង់ទិសឆ្ពោះទៅការធ្វើសមាហរណកម្មចូលក្នុងសហគមន៍អាស៊ាន នៅចុងឆ្នាំ២០១៥ ដូចជា បញ្ហាប្រឈម កាលានុវត្តភាព និងការប្រកួតប្រជែងជាដើម ។